# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៩៨ ក្រ៩" អ "

-ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ៥៨១២ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ៤០៣៩ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ៥៧៩៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៨ និង ៣០ នាទី នៅសាលសវនាការទី៣ ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធាន

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥៨១២ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ចុងភៅ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិតាងួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រ៉ា (ស) ម្តាយឈ្មោះ [redacted] បូនី( ស )នៅលីវ ជានីតិជន ទោសពីមុន គ្មាន( ក្នុងឃុំ )។

- ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(មទ១ )តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៩៧៨១(ហ)ដ.ឃ.ង ចុះថ្ងៃទី២៧.០៨.២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ: **លួច មានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិតាងួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០.០៨.២០២០ បទល្មើស ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

.លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ.

### ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ [redacted] ឆយ៉ុង ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃផ្ទះជួល ភូមិតាងួន សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។



Scanned with CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១០ និង០០នាទី មានជនជាប់ចោទ ចំនួន០២នាក់ មានឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះកុយ ភេទប្រុស អាយុ៣០ឆ្នាំ បានធ្វើសកម្មភាពគាស់បន្ទប់ជួលរបស់ជនរងគ្រោះឈ្មោះ [redacted] ឆយ៉ុង ភេទស្រី ស្ថិតនៅភូមិតាង្គួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហើយបានលួចយកឡេលាបមុខម៉ាក HONG LK SKIN ចំនួន៤០( សែសិប )ក្លង របស់ជនរងគ្រោះ យកទៅបាត់ ។ បន្ទាប់មកជនរងគ្រោះ បានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលកាកាបទី១ លុះដល់ថ្ងៃទី២៣.០៨.២០២០ ជនរងគ្រោះ បានឃើញជនជាប់ចោទឈ្មោះ [redacted] ចិត្រា បង្ហោះឡេលាបមុខម៉ាកHONG LK SKIN នៅក្នុងបណ្តាញសង្គមហ្វេសប៊ុក(face book )ក៏បានណាត់ជនជាប់ចោទមកជួបគ្នា និងបានរាយការណ៍ជូនសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះគ្រុយ ចិត្រា ព្រមទាំងដកហូតវត្ថុតាង ។

-បានឃើញ របាយការណ៍សំយោគលេខ១៥១/២០ រ.ប.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៤២០១ អ.យ.ដ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ៤០៣៩ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៥៥៣៥ អ.យ.ដ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៦៩៦៩(ហ)ង.ដ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាចាត់តាំងតំណាងអយ្យការជំនុំជម្រះលេខ៣៣៥១ អ.យ.ក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្រា នាពេលសវនាការបានឆ្លើយថាកាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១១ និង៣០នាទី ឈ្មោះកុយ បានបបួលខ្លួនទៅយកឡេនៅចំណុចបន្ទប់ជួល ភូមិតាង្គួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពេលខ្លួនជិះកង់តាមឈ្មោះកុយ ទៅដល់ទីតាំងផ្ទះនោះ ខ្លួនបានចាំក្រោមផ្ទះ ហើយឈ្មោះកុយ បានឡើងទៅលើផ្ទះនោះ បន្តិចក្រោយមកឈ្មោះ កុយ បានចុះពីលើផ្ទះនោះវិញ រួចហុចឡេ ចំនួន៤០ ( សែសិប )ក្លង ឱ្យខ្លួនយកទៅលក់ ។ ក្រោយមកនៅថ្ងៃទី២៣.០៨.២០២០ វេលាម៉ោង០៩ និង៣០នាទីព្រឹក ខ្លួនបានយកឡេនោះទៅលក់ឱ្យម្ចាស់គណនីហ្វេសប៊ុក ដែលមានឈ្មោះ ដូចទៅនឹងម៉ាកសម្គាល់ឡេនោះ នៅចំណុចស្ថានីយ៍ប្រេងឥន្ធនៈ PTT នៅជាប់ផ្លូវចូលពេទ្យស្រុក ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួន តែម្តង ។

-តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ឆយ៉ុង នាពេលសវនាការបានឆ្លើយថា:មុនពេលកើតហេតុថ្ងៃទី១៧.៨ ២០២០ ខ្លួនបានចេញពីបន្ទប់ជួលស្ថិតនៅភូមិតាង្គួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ទៅលេងស្រុកកំណើតនៅខេត្តកំពង់ស្ពឺ ដោយបានត្រឡប់មកវិញ នៅថ្ងៃទី១៩.០៨.២០២០ វេលាម៉ោង១០ព្រឹក ខ្លួនបានឃើញសោរបន្ទប់មានស្នាមគាស់ ទ្វារផ្ទះចំហរ មានឥវ៉ាន់រាយប៉ាយ ដោយមានបាត់ឥវ៉ាន់ជាច្រើនដូចជាឡេលាបមុខ ចំនួន១២០ក្លង ទឹកអប់ ចំនួនចំនួន១០ដប ,ម៉ាស់ចំនួន២ដុំ ,សារ៉ូមចំនួន៨ប្រអប់ ,កាតគ្រីម៉ូតូ ចំនួន០១ ,កង្ហារទឹកធំ ចំនួន០១,ស្តីកឃើ



Scanned with CamScanner

ចំនួន០១ ,កាំមេរ៉ាម៉ាកCANO ចំនួន០១គ្រឿង ,ទូរស័ព្ទម៉ាក METU ចំនួន០១គ្រឿង ,អាយផេត ចំនួន០១ និងសំលៀកបំពាក់មួយចំនួន សរុបទាំងអស់មានតម្លៃជាទឹកប្រាក់ ចំនួន ៤000ដុល្លាអាមេរិក( បួនពាន់ដុល្លាអាមេរិក )។នៅថ្ងៃមិនចាំ ខែសីហា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះគ្រុយ ចិត្រា បានទាក់ទងតាមទូរស័ព្ទ ដោយប្រាប់ថាមានផលិតផលលក់ ពេលនោះខ្លួនក៏សុំអាខោនហ្វេសបុក ដើម្បីខលវីដេអូមើលសម្ភារៈផលិតផល ដែលគេចង់លក់ឲ្យខ្លួន ពេលមើលវីដេអូខល ខ្លួនបានស្គាល់ផលិតផលរបស់ខ្លួន ហើយខ្លួនក៏បានណាត់ឲ្យយកផលិតផលនោះមកលក់ឲ្យខ្លួន ខ្លួនក៏ប្តឹងសមត្ថកិច្ច ដល់ថ្ងៃជនជាប់ចោទ យកផលិតផលមកឲ្យខ្លួន សមត្ថកិច្ចក៏ចាប់ និងប្រមូលផលិតផលរបស់ខ្លួន បានឡេចំនួន៤០ក្លង ។

សំណូមពរៈសុំទាមទារទ្រព្យសម្បត្តិដែលបាត់បង់ ចំនួន ៤.០០០ដុល្លាអាមេរិក( បួនពាន់ដុល្លាអាមេរិក )។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted] ភក្ត្រា នៅចៅក្រមស៊ើបសួរបានឆ្លើយថាៈមុនពេលកើតហេតុថ្ងៃទី១៧.៨ ២០២០ ខ្លួនបានចេញពីបន្ទប់ជួលស្ថិតនៅភូមិតាងួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ទៅលេងស្រុកកំណើតនៅខេត្តកំពង់ស្ពឺ ដោយបានត្រឡប់មកវិញ នៅថ្ងៃទី១៩.០៨.២០២០ វេលាម៉ោង១០ព្រឹក ខ្លួនបានឃើញសោរបន្ទប់មានស្នាមគាស់ បន្ទាប់មកខ្លួនបានចូលទៅមើលក្នុងបន្ទប់ឃើញឥវ៉ាន់រាយប៉ាយពេញបន្ទប់ ហើយខ្លួនបានមើលឥវ៉ាន់ឃើញបាត់បង់ដូចជាកាំមេរ៉ាម៉ាក CANO ចំនួន០១គ្រឿង ,កាតគ្រីម៉ូតូ ចំនួន០១ ,កង្ហារទឹកធំ ចំនួន០១ ,អាយផេត ចំនួន០១ ទូរស័ព្ទ ចំនួន០១គ្រឿង,បាស់ចំនួន០១ ,ដងឡាយ ចំនួន០១ និងឥវ៉ាន់ផលិតផលរបស់ប្រពន្ធខ្លួន មួយចំនួនធំ សរុបទាំងអស់មានតម្លៃជាទឹកប្រាក់ចំនួន៤.០០០ដុល្លាអាមេរិក( បួនពាន់ដុល្លាអាមេរិក )។ នៅថ្ងៃមិនចាំ ខែសីហា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ[redacted] ចិត្រា បានទាក់ទងតាមទូរស័ព្ទមកប្រពន្ធរបស់ខ្លួន ដើម្បីទិញលក់ផលិតផល ក្រោយមកបានណាត់គ្នាប្រគល់ផលិតផល ពេលជនជាប់ចោទប្រគល់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន រួមជាមួយឡេ ចំនួន ៤០ក្លង តែម្តង ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈតាមចម្លើយសារភាពរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់គ្នាទៅនឹងវត្ថុចាប់យក ដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទ ។ដូច្នេះតំណាងអយ្យការសុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ៥៥៣៥ អ.យ.ដ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ នៅដដែល ។

.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថាៈកូនក្តីខ្លួនបានឆ្លើយសារភាពថាពិតជាបានទទួលឡេពីឈ្មោះកុយ ឲ្យយកទៅលក់ពិតប្រាកដ មែន តែពុំបានដឹងថាឡេនេះឈ្មោះកុយ លួចគេទេ ។ សុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទៈសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

១-កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១០ និង០០នាទី ជនជាប់ចោទ ចំនួន០២នាក់ មានឈ្មោះ[redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះកុយ ភេទប្រុស អាយុ៣០ឆ្នាំ បានធ្វើសកម្មភាពគាស់បន្ទប់ជួលរបស់ជនរងគ្រោះឈ្មោះ[redacted] ឆយ៉ុង ភេទស្រី ស្ថិតនៅភូមិតាងួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហើយបានលួចយកឡេលាបមុខម៉ាក HONGLK SKIN ចំនួន៥០( សែសិប )ក្នុងរបស់ជនរងគ្រោះ យកទៅបាត់ ។ បន្ទាប់មកជនរងគ្រោះបានដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលកាកាបទី១ លុះដល់ថ្ងៃទី២៣.០៨.២០២០ ជនរងគ្រោះបានឃើញជនជាប់ចោទឈ្មោះ[redacted] ចិត្រា បង្ហោះឡេលាបមុខម៉ាក HONGLK SKIN នៅក្នុងបណ្ដាញសង្គមហ្វេសប៊ុក (facebook )ក៏បានណាត់ជនជាប់ចោទមកជួបគ្នា និងបានរាយការណ៍ជូនសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះ[redacted] ចិត្រា ព្រមទាំងដកហូតវត្ថុតាង ។

២-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៦៩៦៩(ហ)ដ.ដ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ[redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ: លួច មានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់ជួល តាងួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០.០៨.២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ជនជាប់ចោទឈ្មោះ កុយ ភេទប្រុស អាយុ៣០ឆ្នាំ(គេចខ្លួនគ្មានសាវតាជាតិ) ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លើកលែងចោទប្រកាន់តាមដីកាលេខ៦៩៦៨( ហ )ដ.ដ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ រួចហើយ ។

៤-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ មានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ដើមបណ្ដឹងឈ្មោះ[redacted] ឆយ៉ុង ,ចម្លើយសាក្សីឈ្មោះ[redacted] ភក្ត្រា និងរបាយការណ៍សំយោគលេខ១៥១/២០ រ.ប.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ក៏ដូចជាវត្ថុតាងដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទ ។

៥-ជនជាប់ចោទឈ្មោះ[redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយ ដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះ មានវិបល្លាសស្មារតី ក្នុងពេលប្រព្រឹត្តបទល្មើសទេ ។ ជននេះមានការពិចារណាយល់ដឹងអំពីផលវិបាកកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌ នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៦-អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ ធ្វើឱ្យប៉ះពាល់ដល់សុខភាព និងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គម សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ។ អំពើនេះជាអំពើល្មើស ដែលមានចែងឱ្យផ្តន្ទាទោសតាមប្បញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ[redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ពីបទ:លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់ជួលតាងួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០.០៨.២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមពហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៨-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆយ៉ុង ប្ដឹងទាមទារសំណងចំនួន ៤.០០០ដុល្លាអាមេរិក( បួនពាន់ ) ។ គប្បីតុលាការពិនិត្យ និងសម្រេច ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោសលើ៖

.ឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ( ដែលមានសាវតាជាតិ ដូចខាងលើ ) ។

ដាក់ពន្ធនាគារកំណត់រយៈពេល៣ឆ្នាំ( **បីឆ្នាំ** ) ។

ពីបទ: **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលតាង្គួន១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០.០៨.២០២០ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ចិត្រា សងសំណងទៅដើមបណ្ដឹងឈ្មោះ [redacted] ឆយ៉ុង ចំនួន ៤០០០ដុល្លាអាមេរិក( បួនពាន់ ) ។ ការទាមទារលើសពីនេះបដិសេធចោល ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិត្រា ,ដើមបណ្ដឹងឈ្មោះ [redacted] ឆយ៉ុង ,មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: |

[redacted]

..........................................................................................................

( បានចម្លងត្រឹមត្រូវតាមច្បាប់ដើម )

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]